**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

លេខ ១៥៧/ គ.ជ.ប
/០៧

# សូមជំរាបជូន

## ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

**កម្មវត្ថុ** : សំណើជួយអន្តរាគមន៍ទៅគ្រប់ម្ចាស់រោងចក្រ សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យកម្មករ និយោជិត បានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃ អាទិត្យ ទី ០១ ខែ មេសា ឆ្នាំ ២០០៧ ។

**យោង** : - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៧ ។

តបតាមកម្មវត្ថុ និង យោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជំរាបឯកឧត្តម រដ្ឋមន្ត្រី ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈជ្រាបថា នៅថ្ងៃ អាទិត្យ ទី ០១ ខែ មេសា ឆ្នាំ ២០០៧ ខាងមុខនេះ ជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២ ឆ្នាំ ២០០៧ ។

អាស្រ័យហេតុនេះដើម្បីសម្រួលដល់កម្មករ និយោជិត នៅតាមបណ្តារោងចក្រ សហគ្រាសទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ ឆ្នាំ ២០០៧ សូមឯកឧត្តមរដ្ឋមន្ត្រីជួយអន្តរាគមន៍ទៅគ្រប់ម្ចាស់រោងចក្រ សហគ្រាសទាំងអស់ ដើម្បីឱ្យកម្មករ និយោជិត បានទៅបោះឆ្នោតតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រី ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ ៣ ឆ្នាំ ២០០៧

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

អ៊ឹម_សុស៊ី

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- ឯកសារ កាលប្បវត្តិ